
www.kidsofdestiny.org
Kids of Destiny®

# 1.13 យ៉ាកុបត្រលប់នៅផ្ទះវិញ

លោកយ៉ាកុបបានមកដល់ទឹកដីម្តាយរបស់គាត់។ គាត់បានជួបបងប្អូនប្រុសរបស់ម្តាយគាត់ឈ្មោះឡាបាន់និងបានរៀបការជាមួយកូនស្រីគាត់ឈ្មោះលេអា និងរ៉ាជែល។ គាត់បានបន្តរស់នៅ និងធ្វើការឱ្យឡាបាន់អស់ជាច្រើនឆ្នាំ។ លោកឡាបាន់ធ្វើបាបយ៉ាកុបដោយអយុត្តិធម៌។ ព្រះបានមានបន្ទូលទៅកាន់យ៉ាកុប ហើយបានប្រាប់គាត់ឲ្យត្រឡប់ទៅស្រុករបស់ឪពុកគាត់ គឺលោកអ៊ីសាកនិងជីតារបស់គាត់អ័ប្រាហាំវិញ។ ព្រះទ្រង់បានមានបន្ទូលថា៖ «ខ្ញុំនឹងនៅជាមួយអ្នក»។ លោកឡាបាន់ខឹងនឹងលោកយ៉ាកុប ពីព្រោះលោកយ៉ាកុបបានទទួលជោគជ័យ។

បើលោកឡាបាន់បង់សត្វឲ្យលោកយ៉ាកុបសម្រាប់ការងារ ដែលគាត់បានធ្វើឲ្យលោកឡាបាន់ នោះសត្វរបស់លោកយ៉ាកុបមានសុខភាពល្អជាងសត្វចិញ្ចឹមគាត់ ហើយហ្វូងសត្វរបស់គាត់ក៏កើនឡើងដែរ។ បើលោកឡាបាន់សម្រេចចិត្តឲ្យហ្វូងសត្វនៅចំពោះមុខគាត់ និងលោកយ៉ាកុបរស់នៅផ្គុំគ្នា សត្វរបស់លោកយ៉ាកុបនៅតែល្អជាងគេ។ ភរិយារបស់លោកយ៉ាកុប គឺលេអានិងរ៉ាជែលបានយល់ព្រមជាមួយគាត់ អំពីការចាកចេញរបស់ពួកគេ។ ពួកគេនិយាយថា "យើងគ្មានហេតុផលដើម្បីស្នាក់នៅទីនេះទេ"។ "ឪពុករបស់យើងនឹងមិនផ្តល់ឱ្យយើងនូវទ្រព្យសម្បត្តិណាមួយរបស់គាត់ឡើយ។ យើងត្រូវទៅមុខ ហើយធ្វើអ្វីដែលព្រះបានប្រាប់អ្នកឱ្យធ្វើចុះ"។

លោកយ៉ាកុបបានដាក់ប្រពន្ធនិងកូនៗរបស់គាត់នៅលើខ្នងអូដ្ឋ។ គាត់បានដាក់ហ្វូងសត្វទាំងអស់របស់គាត់នៅពីមុខពួកគេ។ គាត់បានប្រមូលតវ៉ាន់ទាំងអស់របស់គាត់។ ហើយពួកគេបានចាកចេញយ៉ាងឆាប់រហ័ស ទៅស្រុកកាណានជាកន្លែង ដែលលោកអ៊ីសាកជាឪពុករបស់គាត់រស់នៅ។ នៅពេលដែលលោកឡាបាន់បានដឹងថា ពួកគេបានចេញទៅបាត់ហើយ លោកឡាបាន់ក៏មកតាមរកលោកយ៉ាកុប។ ហេតុអ្វីបានជាអ្នកនាំកូនស្រី និងចៅរបស់យើងទៅឆ្ងាយដូច្នេះ? គាត់បានសួរយ៉ាកុប។ លោកយ៉ាកុបមានប្រសាសន៍ទៅកាន់លោកឡាបាន់ថា៖ «ខ្ញុំបានធ្វើការឲ្យលោកអស់រយៈពេលម្ភៃឆ្នាំហើយ។ ខ្ញុំបានធ្វើការយ៉ាងនឿយហត់ក្នុងអំឡុងពេលថ្ងៃក្តៅ និងយប់ត្រជាក់។ ប៉ុន្តែលោកនៅតែអយុត្តិធម៌ចំពោះខ្ញុំ។ ខ្ញុំបានចាកចេញយ៉ាងលឿន ពីព្រោះខ្ញុំខ្លាចលោកឪពុកដកយកប្រពន្ធខ្ញុំពីខ្ញុំដោយបង្ខិតបង្ខំវិញ"។

លោកយ៉ាកុប និងលោកឡាបាន់បានធ្វើកិច្ចព្រមព្រៀងមួយនៅចំពោះព្រះ ហើយពួកគេទាំងអស់គ្នាក៏ធ្វើពិធីជប់លៀងមួយ។ ពួកគេបានយល់ព្រមមិនធ្វើបាបគ្នាទៀតទេ។ ពួកគេបានយល់ព្រមថា ព្រះនឹងធ្វើជាសាក្សីចំពោះទង្វើរបស់ពួកគេ។ លោកឡាបាន់ថើបកូនស្រីនិងចៅរបស់គាត់ ហើយប្រទានពរដល់ពួកគេ។ បន្ទាប់មកឡាបាន់ត្រឡប់មកផ្ទះវិញ។ លោកយ៉ាកុបបន្តដំណើរទៅមុខទៀត។ គាត់បានដឹងថាគាត់នឹងជួបបងប្រុសរបស់គាត់ឈ្មោះអេសាវនៅតាមផ្លូវ។ គាត់បានចាត់អ្នកនាំសារ ឲ្យទៅជូនកាដូដល់បងប្រុសរបស់គាត់។

យ៉ាកុបបានចាំពីទង្វើដែលគាត់បានបោកប្រាស់អេសាវអស់ជាច្រើនឆ្នាំមកហើយ ដើម្បីទទួលពរពីឪពុករបស់ពួកគេ។ គាត់ខ្លាចបងប្រុសរបស់គាត់នៅតែខឹងនឹងរឿងនេះ។ លោកយ៉ាកុបបានឃើញលោកអេសាវចូលមកជិតគាត់ជាមួយទាហានបួនរយនាក់! លោកយ៉ាកុបខ្លាចបងប្រុស .របស់គាត់វាយប្រហារគាត់។ គាត់បានអធិស្ឋានហើយសុំព្រះជួយសង្គ្រោះគាត់ពីបងប្រុសរបស់គាត់។ ពេលលោកអេសាវជាបងរបស់យ៉ាកុបបានឃើញគាត់ យ៉ាកុបឱនចុះដល់ដី។ បន្ទាប់មកលោកអេសាវបានរត់ទៅជួបគាត់។

លោកអេសាវឱបគាត់ហើយថើបគាត់។ ពួកគេទាំងពីរបានយំ។ លោកយ៉ាកុបនិងលោកអេសាវម្នាក់ៗ បានដើរតាមផ្លូវរបស់គេរៀងៗខ្លួន។ លោកយ៉ាកុបបន្តធ្វើដំណើរទៅផ្ទះរបស់គាត់។ លោកអេសាវបានធ្វើដំណើរទៅកន្លែងដែលគាត់ត្រូវទៅ។ លោកយ៉ាកុបបានទូលសូមឲ្យព្រះជួយគាត់។ ព្រះអម្ចាស់បានថែរក្សាលោកយ៉ាកុបដូចព្រះអង្គទ្រង់បានសន្យា។ ព្រះក៏បានសង្គ្រោះយ៉ាកុបពីបងប្រុសរបស់គាត់ដែរ។ លោកអេសាវបានអភ័យទោសដល់យ៉ាកុប ហើយពួកគេបានស្រឡាញ់គ្នាទៅវិញទៅមក។ នៅពេលយើងទូលសូមឲ្យព្រះទ្រង់ជួយយើង ទ្រង់អាចឆ្លើយតបនូវការអធិស្ឋានរបស់យើងតាមរបៀបដ៏អស្ចារ្យ។

(លោកុប្បត្តិ ៣១, ៣២ និង ៣៣)

## 1.13 យ៉ាកុបនៅផ្ទះវិញ- សេចក្ដីណែនាំសម្រាប់គ្រូបង្រៀន

### កំណត់សម្គាល់

១) លោកយ៉ាកុបធ្លាប់ធ្វើការឱ្យបងប្អូនប្រុសម្ដាយរបស់គាត់ឈ្មោះឡាបាន់អស់រយៈពេលជាច្រើនឆ្នាំ។ លោកឡាបាន់បានប្រព្រឹត្តដាក់គាត់ដោយអយុត្តិធម៌។ ព្រះទ្រង់បានមានបន្ទូលទៅកាន់យ៉ាកុប ហើយបានប្រាប់គាត់ឲ្យត្រឡប់ទៅផ្ទះវិញនៅឯទឹកដីរបស់ឪពុកគាត់។ ព្រះទ្រង់មានបន្ទូលថា "យើងនឹងនៅជាមួយឯង"។

២) លោកយ៉ាកុបបានយកប្រពន្ធកូន និងសត្វព្រមទាំងរបស់របរទាំងអស់របស់គាត់ ហើយចាកចេញទៅយ៉ាងលឿន។ កាលលោកឡាបាន់ដឹងថាពួកគេចេញទៅបាត់ គាត់ក៏ដេញតាមពីក្រោយពួកគេ ។

៣) ឡាបាន់ពោលថា "ហេតុអ្វីបានជាអ្នកនាំកូនស្រី និងចៅរបស់ខ្ញុំទៅឆ្ងាយដូច្នេះ?" លោកយ៉ាកុបមានប្រសាសន៍ថា៖ «ខ្ញុំបានខំប្រឹងធ្វើការយ៉ាងខ្លាំងឲ្យលោក ហើយលោកបានធ្វើបាបខ្ញុំដោយអយុត្តិធម៌។ ខ្ញុំខ្លាចលោកឪពុកដកយកប្រពន្ធខ្ញុំពីខ្ញុំដោយបង្ខិតបង្ខំ" ។

៤) លោកឡាបាន់និងលោកយ៉ាកុប បានព្រមព្រៀងគ្នានៅចំពោះព្រះ។ ពួកគេយល់ព្រមមិនធ្វើបាបគ្នាទៀតទេ។ ព្រះទ្រង់នឹងធ្វើជាសាក្សីចំពោះទង្វើរបស់ពួកគេ។ ឡាបាន់ថើបកូនស្រីនិងចៅរបស់គាត់បន្ទាប់មកប្រទានពរដល់ពួកគេ។ ក្រោយមកគាត់បានត្រឡប់ទៅផ្ទះរបស់គាត់វិញ ។

៥) លោកយ៉ាកុបដឹងថា គាត់នឹងជួបបងប្រុសរបស់គាត់ឈ្មោះអេសាវ នៅពេលធ្វើដំណើរទៅផ្ទះរបស់គាត់ គាត់ខ្លាចលោកអេសាវនៅតែខឹងនឹងគាត់ដែលគាត់បានទទួលពរពីឪពុកគាត់។ លោកយ៉ាកុបបានទូលសូមព្រះឲ្យជួយសង្គ្រោះគាត់ ពីលោកអេសាវ។ លោកយ៉ាកុបបានលុតជង្គង់ ពេលដែលពួកគេបានឃើញគ្នា។ ទោះបីជាពេលអេសាវរត់មករកគាត់ គាត់បានឱប ហើយថើបយ៉ាកុប ។ អេសាវបានអត់ទោសឱ្យប្អូនប្រុសរបស់គាត់ ។

### សំណួរ:

១) តើអ្វីដែលធ្វើឲ្យលោកយ៉ាកុបសម្រេចចិត្តត្រឡប់ទៅផ្ទះវិញ?

២) តើលោកឡាបាន់បានធ្វើអ្វី នៅពេលដែលគាត់ដឹងថា លោកយ៉ាកុបនិងក្រុមគ្រួសាររបស់គាត់បានបាត់បង់?

៣) តើលោកឡាបាន់ និងលោកយ៉ាកុបបានធ្វើកិច្ចព្រមព្រៀងអ្វីចំពោះព្រះ?

៤) ហេតុអ្វីលោកយ៉ាកុបខ្លាច ពេលគាត់បន្តដំណើរទៅផ្ទះវិញ?

៥) ពេលលោកអេសាវបានឃើញប្អូនប្រុសរបស់គាត់ឈ្មោះយ៉ាកុប តើគាត់បានធ្វើអ្វីខ្លះ?

### ចម្លើយ:

១) លោកយ៉ាកុបសម្រេចចិត្តវិលត្រឡប់ទៅផ្ទះវិញពីព្រោះលោកឡាបាន់បាន ធ្វើបាបគាត់ដោយអយុត្តិធម៌ ។

២) លោកឡាបាន់ដេញតាមក្រោយពួកគេ នៅពេលដែលគាត់ដឹងថាយ៉ាកុបនិងគ្រួសាររបស់គាត់បានបាត់បង់។

៣) លោកឡាបាន់ និងយ៉ាកុបបានព្រមព្រៀងនៅចំពោះព្រះថា ពួកគេនឹងមិនធ្វើបាបគ្នាទៀតទេ ។

៤) យ៉ាកុបខ្លាចព្រោះគាត់ដឹងថា គាត់នឹងជួបបងប្រុសរបស់គាត់ឈ្មោះអេសាវ ។

៥) ពេលលោកអេសាវបានឃើញប្អូនប្រុសរបស់គាត់ឈ្មោះយ៉ាកុប គាត់រត់មករកគាត់ហើយឱបថើបគាត់ ។


www.kidsofdestiny.org